# ជំងឺ COVID-19៖ ការពិតនៃថ្នាំបង្ការ
# ការមានផ្ទៃពោះ និងការបំបៅដោះកូន




## ហេតុអ្វីត្រូវទទួលចាក់ថ្នាំបង្ការ?

- អ្នកជំនាញផ្នែកផ្ទៃពោះ **ណែនាំឱ្យទទួលចាក់ថ្នាំបង្ការជំងឺ COVID-19** សម្រាប់មនុស្សទាំងឡាយដែលមានផ្ទៃពោះ ឬកំពុងបំបៅដោះកូន។ នេះរួមបញ្ចូលទាំងការចាក់ដូសជំរុញនៃថ្នាំបង្ការជំងឺ COVID-19 នៅពេលដល់ពេលវេលាអាចទទួលចាក់វាបាន។
- ប្រសិនបើអ្នកមានផ្ទៃពោះ ឬធ្លាប់មានផ្ទៃពោះនាពេលថ្មីៗនេះ អ្នកទំនងជាអាចធ្លាក់ខ្លួនឈឺធ្ងន់ធ្ងរដោយសារជំងឺ COVID-19 បើធៀបទៅនឹងអ្នកដែលមិនមានផ្ទៃពោះ។
- ប្រសិនបើអ្នកឆ្លងជំងឺ COVID-19 ខណៈពេលអ្នកកំពុងមានផ្ទៃពោះ អ្នកប្រឈមនឹងហានិភ័យខ្ពស់ជាងមុនក្នុងការមានផលវិបាកនានា ដូចជាទារកកើតមិនគ្រប់ខែ និងទារកស្លាប់ក្នុងផ្ទៃ។



- ការទទួលចាក់ **ថ្នាំបង្ការជំងឺ COVID-19 អាចការពារអ្នក និងទារករបស់អ្នក** ពីការធ្លាក់ខ្លួនធ្ងន់ធ្ងរខ្លាំងដោយសារជំងឺ COVID-19។ ការរក្សាសុខភាពឱ្យបានល្អតាមដែលអាចធ្វើទៅបានក្នុងពេលមានផ្ទៃពោះ គឺមិនត្រឹមតែសំខាន់សម្រាប់សុខភាពរបស់អ្នកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងសំខាន់ចំពោះសុខភាពទារករបស់អ្នកផងដែរ។ ប្រព័ន្ធការពារដែលអ្នកទទួលបានពីថ្នាំបង្ការ ក៏ត្រូវបានបញ្ជូនទៅទារករបស់អ្នក និងជួយរក្សាសុវត្ថិភាពពួកគេក្នុងអំឡុងពេលប៉ុន្មានខែដំបូងនៃជីវិតរបស់ពួកគេផងដែរ។

## ពេលដែលត្រូវទៅទទួលចាក់ថ្នាំបង្ការ

- ថ្នាំបង្ការអាចត្រូវបានផ្តល់ជូន **នៅដំណាក់កាលណាមួយនៃការមានផ្ទៃពោះក៏បាន** ឬនៅពេលកំពុងបំបៅដោះកូន។
- មនុស្សភាគច្រើនត្រូវការថ្នាំបង្ការប្រភេទ Pfizer ឬប្រភេទ Moderna ចំនួន 2 ដូសសម្រាប់លំដាប់ដំបូងរបស់ពួកគេ ហើយនិងដូសជំរុញក្នុងរយៈពេល 5 ខែក្រោយមកទៀត។ មនុស្សដែលមានប្រព័ន្ធភាពស៊ាំខ្សោយប្រហែលជាត្រូវទទួលចាក់ដូសបន្ថែម និង/ឬដូសជំរុញទីពីរ ហើយគួរតែពិគ្រោះជាមួយគ្រូពេទ្យរបស់ពួកគេ។ សម្រាប់ព័ត៌មានលម្អិត សូមមើលកាលវិភាគនៃការចាក់ថ្នាំបង្ការនៅលើគេហទំព័រ ph.lacounty.gov/VaccineAppointment។



## ចុះបើនិយាយអំពីសុវត្ថិភាពវិញ?

- មនុស្សដែលមានផ្ទៃពោះរាប់ពាន់នាក់ **បានទទួលចាក់ថ្នាំបង្ការជំងឺ COVID-19 ដោយសុវត្ថិភាព**។ មិនមានរបាយការណ៍ណាមួយអំពីការកើនឡើងនៃហានិភ័យចំពោះការរលូតកូន ទារកស្លាប់ក្នុងផ្ទៃ បញ្ហាលូតលាស់ ឬពិការភាពពីកំណើតនោះទេ។
- ប្រសិនបើអ្នកមានសំណួរផ្សេងៗ **សូមពិគ្រោះជាមួយគ្រូពេទ្យរបស់អ្នក**។ អ្នកក៏អាចទូរស័ព្ទទៅលេខ 866- 626-6847 ផ្ញើសារជាអក្សរទៅលេខ 855.999.8525 ផ្ញើអ៊ីម៉ែលទៅ ContactUs@mothertobaby.org ឬចាប់ផ្តើមការជជែកគ្នានៅលើគេហទំព័រ mothertobaby.org/ask-an-expert ផងដែរ។



## ថ្នាំបង្ការគឺឥតគិតថ្លៃសម្រាប់មនុស្សគ្រប់គ្នា - បើទោះបីជាអ្នកមិនមានធានារ៉ាប់រងក៏ដោយ

អ្នកនឹងមិនត្រូវបានសួរនាំអំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ។ មានទីតាំងចាក់ថ្នាំបង្ការជាច្រើនកន្លែងនៅទូទាំងខោនធី LA - ដែលទីតាំងជាច្រើនបើកបម្រើការជូននៅចុងសប្តាហ៍និងពេលល្ងាច ហើយមិនចាំបាច់ធ្វើការណាត់ជួបទេ។ ដើម្បីស្វែងរកទីតាំងនៅក្នុងតំបន់ជិតរបស់អ្នក៖

- សូមចូលទៅកាន់គេហទំព័រ **VaccinateLACounty.com** ឬទូរស័ព្ទទៅលេខ **833-540-0473** បម្រើការជូនចាប់ពីម៉ោង 8:00 ព្រឹកដល់ម៉ោង 8:30 យប់។
- អ្នកក៏អាចទូរស័ព្ទទៅលេខ 2-1-1 ឬសាកសួរគ្រូពេទ្យ ឬឱសថការីក្នុងតំបន់របស់អ្នកបានផងដែរ។
- ការដឹកជញ្ជូនដោយឥតគិតថ្លៃ និងការចាក់ថ្នាំបង្ការនៅតាមផ្ទះក៏មានផ្តល់ជូនផងដែរ។